**សម្រាប់ផ្សព្វផ្សាយភ្លាម**

**ទំនាក់ទំនង:** *នៅភ្នំពេញ:* ប៊ូ សារឿន (៨៥៥) ០២៣-២១៧-៣០១
sbou@worldbank.org

# ធនាគារពិភពលោកនិងពហុស្ថាប័នដៃគូអភិវឌ្ឍន៍ ជួយកម្ពុជាក្នុងការកែលម្អអភិបាលកិច្ចល្អ និងសេវាសុខភាព

**ភ្នំពេញ ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៩** - នៅថ្ងៃនេះ រាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណងចំនួនពីរដែលមានទឹកប្រាក់សរុបចំនួន ៧២,១ លានដុល្លារ ជាមួយធនាគារពិភពលោក និងពហុស្ថាប័នដៃគូអភិវឌ្ឍន៍។ កិច្ចព្រមព្រៀង ទាំងនេះផ្តល់នូវជំនួយឧបត្ថម្ភហិរញ្ញវត្ថុដ៏សំខាន់ជូនដល់គម្រោងអភិវឌ្ឍន៍ផ្សេងៗគ្នាចំនួនពីរដែលរួមគ្នាសំដៅលើកស្ទួយជីវភាពរបស់ប្រជាជន និងកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។

កិច្ចព្រមព្រៀងទីមួយ ដែលមានទឹកប្រាក់ចំនួន ២០ លានដុល្លារអាមេរិក គាំទ្រគម្រោងទាមទារឱ្យមានអភិបាលកិច្ចល្អ (DFGG) ដែលសំដៅកែលម្អគណនេយ្យភាពនិងភាពឆ្លើយតបរបស់រាជរដ្ឋាភិបាលចំពោះសេចក្តីត្រូវការរបស់សាធារណជន។ កិច្ចព្រមព្រៀងទីពីរ ដែលមានទឹកប្រាក់ចំនួន ៥២,១ លានដុល្លារ ផ្តល់ធនធានបន្ថែមជូនដល់កម្មវិធីគាំទ្រវិស័យសុខាភិបាលទីពីរ (HSSP2) សំដៅជួយរាជរដ្ឋាភិបាលក្នុងការកែលម្អសុខភាពរបស់មាតានិងកុមារក្រីក្រ។

ឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានមានប្រសាសន៍ថា *"កិច្ចព្រមព្រៀងហិរញ្ញប្បទានជំនួយឥតសំណងដែលយើងបានចុះហត្ថលេខាថ្ងៃនេះ នឹងរួមចំណែកដល់សសរទ្រូងទីបួននៃយុទ្ធសាស្ត្រចតុកោណកម្ពុជា។ យើងទទួលស្គាល់ការទទួលខុសត្រូវរបស់យើងក្នុងការប្រើប្រាស់ហិរញ្ញប្បទានឥតសំណងទាំងនេះ ប្រកបដោយគណនេយ្យភាព និង តម្លាភាព។ យើងសូមអះអាងជាថ្មីនូវការប្តេជ្ញាចិត្តនិងឆន្ទៈដ៏រឹងមាំរបស់យើងចំពោះការអនុវត្តសេចក្តីប្រកាសដោយរាជរដ្ឋាភិបាលកម្ពុជានិងដៃគូអភិវឌ្ឍន៍ ស្តីពីសុខុដុមនីយកម្ម និងការតម្រឹម ដើម្បីកែលម្អការសម្របសម្រួល និងភាពជាដៃគូអភិវឌ្ឍន៍ និងដើម្បីប្រកាន់យកភាពជាអ្នកដឹកនាំលើអាទិភាពអភិវឌ្ឍន៍ និងដើម្បីងាកចេញពីកិច្ចអភិវឌ្ឍន៍ដែលនាំមុខដោយស្ថាប័នផ្តល់ជំនួយ ឆ្ពោះទៅកាន់កិច្ចអភិវឌ្ឍន៍ដែលដឹកនាំដោយប្រទេសកម្ពុជានិងប្រជាជនរបស់ខ្លួន។"*

នាយកប្រចាំប្រទេសធនាគារពិភពលោកប្រចាំប្រទេសកម្ពុជា លោកស្រី **អាណែត ឌិកសិន** (Annette Dixon) មានប្រសាសន៍ថា ទាំងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍កំពុងតែផ្តោតអាទិភាពទៅលើការអភិវឌ្ឍអភិក្រមទូទាំងកម្មវិធី

និងធ្វើការតាមបែបជាដៃគូប្រកបដោយសុខុដុមនីយកម្ម និងការតម្រឹម ដើម្បីលើកកំពស់ភាពជាម្ចាស់របស់រដ្ឋាភិបាល។ លោកស្រី មានប្រសាសន៍បន្តថា *"គំរោងទាំងនេះនឹងនាំយើងមួយជំហានទៀតទៅរកការសម្របតាមយុទ្ធសាស្ត្រ និងប្រព័ន្ធរបស់ប្រទេស ។ ខ្ញុំជឿថាជំនួយឥតសំណងទាំងនេះនឹងជួយផ្តល់ការគាំទ្រយ៉ាងសំខាន់ដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការកាត់បន្ថយភាពក្រីក្រ និងធានាថាប្រជាជនកម្ពុជាមាននិរន្តភាព និងរីករាយក្នុងជីវភាពរស់នៅ"* ។

ប្រធានគ្រប់គ្រងក្រសួងអភិវឌ្ឍន៍អន្តរជាតិអង់គ្លេស (DFID) ប្រចាំប្រទេសកម្ពុជា លោកស្រី **រ៉ូត អានទ្រេយ៉ាវ៉ា** (Ruth Andreyeva) មានប្រសាសន៍ថា *"ខ្ញុំសប្បាយរីករាយណាស់ដែលដៃគូផ្តល់ជំនួយបង្កើតកម្មវិធីថ្មីនេះជាមួយរដ្ឋាភិបាលកម្ពុជា ។ ក្នុងការជំរុញល្បឿននៃការរីកចំរើនលើវិស័យសុខាភិបាលរបស់កម្ពុជាឆ្ពោះទៅសំរេចឱ្យបាននូវគោលដៅ វត្តមានភាពជាដៃគូថ្មីនេះ គឺជាជំហានដ៏សំខាន់មួយឆ្ពោះទៅរក ប្រសិទ្ធិភាពជំនួយនៅក្នុងវិស័យសុខាភិបាល ។ ជាមួយនឹងកាប្តេជ្ញាចិត្តរបស់ដៃគូអភិវឌ្ឍន៍ផ្សេងៗទៀត និងរដ្ឋាភិបាលដែលបានចុះ ហត្ថលេខាស្តីអំពីភាពជាដៃគូផ្នែកសុខភាពអន្តរជាតិ កាលពីខែ កញ្ញា ឆ្នាំ ២០០៧ កម្មវិធីថ្មីនេះ ដាក់បញ្ចូលនូវផែនដាក់ធនធាន និងពេលកម្មរួមគ្នាដោយមធ្យោបាយសហការប្រសើរមួយរវាងដៃគូអភិវឌ្ឍន៍នានា ដើម្បីជួយគាំទ្រដល់ក្រសួងសុខាភិបាល"* ។

លេខាទីមួយទទួលបន្ទុកលើកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ (AusAID) លោកស្រី **អាធី ប៉ាថុល** (Arthi Patel) បានមានប្រសាសថា: *"AusAID មានសេចក្តីរីករាយក្នុងការចូលរួមជាមួយដៃគូអភិវឌ្ឍន៍ផ្សេងទៀតដើម្បីវិនិយោគលើការកែលម្អសេវាសុខភាព និងបរិស្ថានអភិបាលកិច្ចនៅកម្ពុជា។ កម្មវិធីគាំទ្រវិស័យសុខាភិបាលទីពីរ នឹងបង្រួបបង្រួមធនធាននៅពីក្រោយប្រព័ន្ធសុខាភិបាលរបស់រាជរដ្ឋាភិបាល ដើម្បីសម្រេចបាននូវការកែលម្អជាក់ស្តែងនៅក្នុងសុខភាពរបស់មាតានិងកុមារ។ គម្រោងទាមទារឱ្យមានអភិបាលកិច្ចល្អ នឹងជម្រុញឱ្យមានភាពជាដៃគូថ្មីរវាងប្រជាពលរដ្ឋនិងរដ្ឋ ដែលនាំទៅដល់អភិបាលកិច្ចប្រកបដោយគណនេយ្យភាពនិងតម្លាភាពកាន់តែច្រើនឡើងនៅថ្នាក់ជាតិ ខេត្ត និងមូលដ្ឋាន។"*

គម្រោង DFGG ដែលត្រូវបានជួយឧបត្ថម្ភដោយធនាគារពិភពលោក ជាមួយទឹកប្រាក់ចំនួន ២0 លានដុល្លារ និងទីភ្នាក់ងារអូស្ត្រាលីដើម្បីកិច្ចអភិវឌ្ឍន៍អន្តរជាតិ (AusAID) ចំនួន ៣,៦២ លានដុល្លារ សំដៅពង្រឹងលទ្ធភាពរបស់ប្រជាពលរដ្ឋក្នុងការទាមទារឱ្យមានអភិបាលកិច្ចកាន់តែប្រសើរឡើងនៅក្នុងវិស័យកំណែទម្រង់ចំនួនបួន ពោលគឺអភិវឌ្ឍន៍ផ្នែកឯកជន ការគ្រប់គ្រងធនធានធម្មជាតិ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងវិមជ្ឈការនិងភាពជាដៃគូរបស់ប្រជាពលរដ្ឋដើម្បីអភិបាលកិច្ចល្អប្រសើរ។ គម្រោងនេះនឹងធ្វើកិច្ចការនេះដោយគាំទ្រស្ថាប័នរដ្ឋនិងស្ថាប័ន

មិនមែនរដ្ឋមួយចំនួនក្នុងការអនុវត្តន៍ កម្មវិធីនិងគំនិតផ្តួចផ្តើមនានាដែលលើកស្ទួយការផ្តល់មតិយោបល់របស់ប្រជាពលរដ្ឋទន្ទឹមគ្នានឹងការជម្រុញឱ្យមានការពាក់ព័ន្ធ និង ភាពជាដៃគូក្នុងលក្ខណៈស្ថាបនារវាងសង្គមស៊ីវិល និងរាជរដ្ឋាភិបាល។ **ព័ត៌មានបន្ថែមអំពីគម្រោង DFGG សូមមើលសេចក្តីប្រកាសដែលបានចេញផ្សាយកាលពីពេលមុននៅថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០០៨។**

ជំនួយឥតសំណងក្នុងទឹកប្រាក់ចំនួន ៥២,១ លានដុល្លារសម្រាប់កម្មវិធី HSSP2 (២០០៨-២០១៣)នេះ ទទួលហិរញ្ញប្បទាន ពីមូលនិធិពហុស្ថាប័នផ្តល់ជំនួយមួយដែលទទួលវិភាគទានពីក្រសួងអភិវឌ្ឍន៍អន្តរជាតិអង់គ្លេស (DFID) ជាប្រាក់ចំនួន ៣៥ លានផោនអង់គ្លេស និង វិភាគទានពីអង្គការ AusAID ជាទឹកប្រាក់ចំនួន ៣៧,១ លានដុល្លារអូស្ត្រាលី។ វិភាគទានទាំងនេះ គឺបន្ថែមលើវិភាគទាន IDA (ធនាគារពិភពលោក) ចំនួន ៣០ លានដុល្លារអាមេរិកដែលកិច្ចព្រមព្រៀងហិរញ្ញវត្ថុត្រូវបានចុះហត្ថលេខាកាលពីថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៨។ កម្មវិធី HSSP2 ជួយរាជរដ្ឋាភិបាលក្នុងការអនុវត្តន៍ផែនការយុទ្ធសាស្ត្រ សុខាភិបាលកម្ពុជាឆ្នាំ ២០០៨-២០១៥ និងត្រូវបានរំពឹងថានឹងបង្កើនយ៉ាងច្រើននូវធនធានដែលមានដើម្បីលើកស្ទួយសុខភាពរបស់មាតានិងកុមារ ក៏ដូចជាដោះស្រាយបញ្ហាសុខភាពនានា ដូចជារបួសនិងជម្ងឺរ៉ាំរ៉ៃ។ **ដើម្បីព័ត៌មានបន្ថែមអំពីកម្មវិធី HSSP2 សូមមើលសេចក្តីប្រកាសដែលបានចេញផ្សាយកាលពីពេលមុននៅថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៨។**